ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# សេចក្តីប្រកាសព័ត៌មាន

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមជម្រាបជូនសាធារណជនជ្រាបថា ក្រោយពីអនុវត្តសាកល្បងនូវវិធានការការពារសត្វផ្សោតទន្លេមេគង្គមួយរយៈកន្លងមក ក្នុងខេត្តក្រចេះនិងស្ទឹងត្រែង ពិនិត្យឃើញថា វិធានការមួយចំនួនមានប្រសិទ្ធភាព ដូចជាការទប់ស្កាត់ការដាក់មងក្រឡាធំ និងការបង្រ្កាបការប្រើឧបករណ៍ឆក់ នៅក្នុងតំបន់គ្រប់គ្រងសត្វផ្សោត។ ដោយឡែកវិធានការមួយចំនួនទៀត ត្រូវបានពិនិត្យឃើញថា មិនមានភាពចាំបាច់ ដូចជាការហាមឃាត់ការនេសាទដោយប្រើមងក្រឡាតូចជាលក្ខណៈគ្រួសារ សម្រាប់ជីវភាពប្រចាំថ្ងៃ នៅក្នុងតំបន់ការពារសត្វផ្សោត ត្រូវបានអនុញ្ញាតឱ្យប្រើឡើងវិញ។

ការដាក់មងក្រឡាធំ នៅក្នុងតំបន់គ្រប់គ្រងសត្វផ្សោត ដែលប៉ះពាល់ដល់សត្វផ្សោត និងត្រីមេពូជ នឹងមិនត្រូវបានអនុញ្ញាតឱ្យប្រើឡើយ រួមទាំងឧបករណ៍នេសាទខុសច្បាប់ផ្សេងទៀត ពិសេសឧបករណ៍ឆក់ នៅតែប្រឈមចំពោះមុខច្បាប់។ ឆ្លើយតបនឹងការកែសម្រួលវិធានការខាងលើ រាជរដ្ឋាភិបាលបានសម្រេចនិរាករណ៍អនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣ ស្តីពីការកំណត់តំបន់គ្រប់គ្រងសត្វផ្សោតទន្លេមេគង្គ ដោយដាក់ឱ្យអនុវត្តឡើងវិញនូវអនុក្រឹត្យលេខ ១៥៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការបង្កើតតំបន់គ្រប់គ្រងនិងការពារសត្វផ្សោតទន្លេមេគង្គ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ អាជ្ញាធរពាក់ព័ន្ធ និងអង្គការ WWF នឹងបន្តធ្វើការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ ដល់ប្រជាពលរដ្ឋ ពង្រឹងការងារល្បាត ស្រាវជ្រាវរកមុខសញ្ញាប្រើឧបករណ៍ឆក់ និងទប់ស្កាត់នូវរាល់សកម្មភាពទាំងឡាយដែលធ្វើឱ្យប៉ះពាល់ដល់និរន្តរភាពសត្វផ្សោត និងត្រីមេពូជនៅក្នុងតំបន់នោះ។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320